**ANNEX 1 : REMAINING [NON-STATEMENT] DOCUMENTS TO BE PUT BEFORE THE CHAMBER**
**[NOT RELATING TO FORCED TRANSFER 1, 2 OR TUOL PO CHREY]]**



**OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN**

| Source | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Closing Order Footnote 3018 | UL Sambath | | | | | | | |

**ពុំមានភាពសមហេតុសមផល។**

**មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**

មានបញ្ជាក់នៅក្នុងកំណត់សម្គាល់ជើងទំព័រ លេខ ៣០២៥ នៃដីកាដំណោះស្រាយ ចម្លើយសារភាពនេះបានបន្ថែមទម្ងន់ទៅលើអំណះអំណាងដែលថា៖ "មូល សម្បត្តិ (ហៅ ញឹម ហៅ រស់ ញឹម ហៅ មូល អ៊ុន) ជាអតីតលេខាគណៈភូមិភាគពាយ័ព្យ រហូតដល់ពេលចាប់ខ្លួនដោយកម្មាភិបាលភូមិភាគនិរតី នាពាក់កណ្ដាលឆ្នាំ ១៩៧៨។"
ឯកសារនេះគឺជាចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម។ អង្គជំនុំជម្រះសាលាដំបូងបានរំលឹកមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មដែលបានចែងថា "រដ្ឋទាំងឡាយត្រូវតែធានាថា រាល់ចម្លើយសារភាពទាំងឡាយ ដែលទទួលបានមកពីការធ្វើទារុណកម្ម មិនអាចត្រូវបានលើកឡើងដើម្បីប្រឆាំងទៅនឹងធាតុផ្សំភ័ស្តុតាងមួយនៅក្នុងនីតិវិធីឡើយ ប្រសិនណាជាពុំមែនត្រូវបានលើកឡើងដើម្បីប្រឆាំងទៅនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដើម្បីបង្ហាញថាពិតជាមានការផ្ដល់សក្ខីកម្មដោយការធ្វើទារុណកម្មកើតឡើងមែននោះ។" ជាក់ស្ដែង លោក ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្មឡើយ ហើយមន្ទីរសន្តិសុខ ស.២១ ពុំស្ថិតនៅក្នុងក្របខណ្ឌ នៃសំណុំរឿង ០០២/១ ឡើយ។ លោក ខៀវ សំផន បានចាត់ទុកថា ឯកសារនេះពុំមានភាពសមហេតុសមផលឡើយ។ ជាក់ស្ដែង វាពិតប្រាកដហើយដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា កថាខណ្ឌនានានៃដីកាដំណោះស្រាយដែល ស្ថិតនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០១ ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ គឺមានចាប់ពីកថាខណ្ឌ ៦៩៨ ដល់ កថខណ្ឌ ៧១១ ។ ដោយឡែក អង្គជំនុំជម្រះបានកម្រិតវិសាលភាពនៃសំណុំរឿង ០០២/១ មកត្រឹមអង្គហេតុដែលពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ ដែលអង្គហេតុទាំងនោះត្រូវបានប្រព្រឹត្តភ្លាមៗ បន្ទាប់ពីមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ដូច្នេះ អង្គជំនុំជម្រះគួរតែពិចារណាតែទៅលើកថាខណ្ឌ ៧០៥ ដល់កថាខណ្ឌ ៧១១ ដែលពាក់ព័ន្ធតែទៅលើអង្គហេតុទាំងនេះ។

ឯកសារនេះមិនអាចឲ្យគេបង្ហាញបានថាចង់បញ្ជាក់អំពីអ្វីនោះទេ។ ជាក់ស្ដែង ផ្ទុយអំពីអ្វីដែលបានលើកឡើងនៅក្នុងផ្ទៃនៃដីកាដំណោះស្រាយ ពុំមានផ្នែកណាមួយនៃឯកសារ ដែលបង្ហាញថា មូល សម្បត្តិ ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលភូមិភាគនិរតី ឬថាគាត់គឺជាលេខានៃគណៈភូមិភាគពាយ័ព្យនោះ។ម្យ៉ាងទៀត អង្គហេតុនេះពុំអាចឲ្យគេបង្ហាញបានថា អតីតមន្ត្រីយោធា និងរដ្ឋការនៃរបប លន់ នល់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃតែ ម្ដងបន្ទាប់ពីមានការរំដោះទីក្រុងភ្នំពេញនោះ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Closing Order Footnote 3025 | rt for Tuol Po | | | | | | | |

**មានលក្ខណៈច្រំដែល។**

**មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**

ឯកសារគឺជារបាយការណ៍ដែលបញ្ជាក់អំពីទីតាំងរបស់ទួលពោធិ៍ជ្រៃដោយសហចៅក្រមស៊ើបអង្កេត។ ក្នុងរបាយការណ៍ មានអត្ថបទសង្ខេបសក្ខីកម្មនានាដែលផ្ដល់ដោយសាក្សី។ ឯកសារនេះមានលក្ខណៈច្រំដែល ដោយហេតុថាកំណត់ហេតុសួរយកចម្លើយសាក្សីទាំងនេះ ព្រមទាំងឯកសារថតសម្លេងកិច្ចសម្ភាសទាំងនេះមាននៅក្នុងសំណុំរឿងរួចទៅហើយ មិនតែប៉ុណ្ណោះ សហព្រះរាជអាជ្ញាមានបំណងចង់ប្រើប្រាស់ឯកសារទាំងនេះធ្វើជាឯកសារភ័ស្តុតាង និង/ឬ សាក្សីត្រូវបានគេកោះហៅឲ្យមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ អ្នកស៊ើបអង្កេតបានបញ្ជាក់ដោយខ្លួនឯងផ្ទាល់ថា"មធ្យោបាយភ័ស្តុតាងតែមួយគត់ដែលច្បាប់ទទួលស្គាល់ គឺអត្ថបទដើមនៃកំណត់ហេតុស្ដាប់យកចម្លើយចុះហត្ថលេខាដោយសាក្សីដូចដែលបានបញ្ជាក់នៅក្នុងបរិបទនេះ។" (ទំព័រ ៨)

ឯកសារនោះក៏បានបញ្ជាក់ផងដែរអំពីព្រឹត្តិការណ៍ដែលកើតមានឡើងនៅតំបន់ពោធិសាត់ ដែលព្រឹត្តិការណ៍ទាំងនោះពុំមែនជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ និងដែលខ្វះនូវភាពសមហេតុសមផល។

**ANNEX 1 : REMAINING [NON-STATEMENT] DOCUMENTS TO BE PUT BEFORE THE CHAMBER [NOT RELATING TO FORCED TRANSFER 1, 2 OR TUOL PO CHREY]]**



**OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN**

| No | Prop. Party | Doc No | Type | Author | Date | Title | K ERN | E ERN | F ERN | Source |
|---|---|---|---|---|---|---|---|---|---|---|
| | អ្នកស៊ើបអង្កេតបានបញ្ជាក់ថា "របាយការណ៍នេះគឺគ្រាន់តែជារបាយការណ៍ដែលបញ្ជាក់អំពីទីតាំងនៃកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មប៉ុណ្ណោះ ហើយពុំមែនជារបាយការណ៍ដែលមានលក្ខណៈបែបវិទ្យាសាស្ត្រ ឬគតិយុត្តិនោះទេ ឬក៏ជារបាយការណ៍រួមស្ដីអំពីឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ ដែលបានកើតមានឡើងនោះទេ។ ជាក់ស្ដែង កិច្ចដែលបានបំពេញ គឺមានត្រឹមតែជាការស៊ើបអង្កេតបឋម និងការងារកសាងអង្គហេតុ (រូបថត រង្វាស់ កូអរដោនេនៃប្រព័ន្ធកំណត់ទីតាំងសាកល (GPS) ការពិព័ណ៌នា រូបគំនូរដោយដៃ ការកំណត់ទីតាំងផ្នូរ) តែមិនមែនជាកិច្ចដែលបានបំពេញជាក់ស្ដែងនោះទេ"។ ដូច្នេះ ឯកសារនេះពុំអាចឲ្យគេបង្ហាញបានថា ចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។<br><br>អ្នកស៊ើបអង្កេតពិតជាបានបញ្ជាក់ថា បានរកឃើញសំបកគ្រាប់កាំភ្លើង ប៉ុន្តែបានបញ្ជាក់ថាពុំមានការជីកកកាយ ឬក៏ពុំមានការប៉ះពាល់ទាំងស្រុងណាមួយទៅលើទីតាំងឧក្រិដ្ឋកម្ម ត្រូវបានធ្វើឡើយ" (ទំព័រ ២១) ហើយថា "សំណល់គ្រាប់រំសេវនៅលើផ្ទៃនៃទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ក៏អាចបញ្ជាក់បានថា មានការវាយប្រយុទ្ធគ្នាកើតឡើងនៅក្នុងភូមិភាគនេះ ហើយមិនមែនជាសំណល់ដែលអាចគិតថា បណ្ដាលមកពីមានការសម្លាប់មនុស្សតែមួយគត់នោះទេ។" របាយការណ៍បញ្ជាក់ពីទីតាំង ៣ កន្លែង ដែលគេសន្មតថាជាកន្លែងបញ្ចុះសាកសពបង្ហាញដោយសាក្សី ដោយនៅទីនោះ សំណល់សម្លៀកបំពាក់លាយឡំជាមួយនឹងដី បង្ហាញឲ្យឃើញថា បានលើកឡើងថា "ពុំមានសេចក្ដីសន្និដ្ឋានដែលគួរឲ្យជឿជាក់បានណាមួយអាចធ្វើទៅបានក្នុងដំណាក់កាលនេះ ដោយពុំមានការគាស់កកាយឡើយ"។ ឯកសារនេះទាំងមូលត្រូវតែបានបដិសេធចោលដោយអង្គជំនុំជម្រះ។ | | | | | | | | | |
| **3** | **Co-Prosecutors** | **E216/3.1** (Different excerpts than E3/40 or IS 3.9) | Book | SUONG Sikoeun | To Be Determined | Book (handwritten) entitled "Odyssey of a Khmer Rouge intellectual : The road to hell is paved with good intentions" | 00829456-00829458, 00829460-00829465 | 00829794-00829796 | 00829797-00829799 | OCP Request E216 partially granted by TC in E216/3 |
| | អង្គជំនុំជម្រះបានបដិសេធចោលនូវសំណើសុំរបស់សហព្រះរាជអាជ្ញា ដែលស្នើឲ្យដាក់បញ្ចូលឯកសារនេះ (E216/3) ដោយហេតុថា ឯកសារនេះពុំមានឡើយនៅមុនពេលដែលមានសក្ខីកម្មរបស់ TCW-694 SUONG Sikoeun។ សាក្សីរូបនេះបានចូលមកបង្ហាញខ្លួនរួចហើយ មានតែអត្ថបទដកស្រង់នៃឯកសារនេះ ដែលមាននៅក្នុងសំណុំរឿងស៊ើបអង្កេតមួយគត់ ដែលត្រូវបានបង្ហាញដោយភាគីដល់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះពុំបានអនុញ្ញាតដល់ភាគីក្នុងការ ប្រើប្រាស់ឯកសារទាំងមូលដើម្បីតាំងសំណួរទៅលើសាក្សីឡើយ។ សាក្សីបានផ្ដល់សក្ខីកម្មពីថ្ងៃទី ២ ដល់ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២។ អង្គជំនុំជម្រះមិនគួរធ្វើការកែប្រែសេចក្ដីសម្រេចរបស់ខ្លួន ដោយលើកហេតុផលថា សហព្រះរាជ អាជ្ញាបានធ្វើការប្រមូលផ្ដុំឯកសារនេះនៅក្នុងបញ្ជីដ៏ត្រឹមត្រូវមួយ ហើយផ្ញើជូនភាគីទាំងអស់នោះ។ ឯកសារនេះពុំមែនជាឯកសារថ្មីមួយដែលពុំទាន់ត្រូវបានគេដាក់ក្នុងកិច្ចពិភាក្សាដេញដោលនៅឡើយនោះទេ។ | | | | | | | | | |
| **4** | **Co-Prosecutors** | **E152.2** | Book | (NUON Chea), Gina CHON, SAMBATH Thet | To Be Determined | Book entitled "Behind the Killing Fields" | 00858214-00858410 | 00757471-00757568 | 00849349-00849484 | TC Decision E190.1 (OCP request E152) |
| | **មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**<br>**មិនអាចទទួលបានក្នុងពេលវេលាមួយសមស្រប។**<br><br>វាគឺជាសៀវភៅមួយក្បាលដែលត្រូវបានសរសេរដោយផ្អែកលើកិច្ចសម្ភាសជាមួយ នួន ជា អស់រយៈពេលជាង ១០០០ ម៉ោង ។ ខ្សែវីដេអូនៃបទសម្ភាសនេះពុំទាន់ត្រូវបានដាក់ជូនអង្គជំនុំជម្រះនៅឡើយទេ។ នៅខណៈដែលគេពុំទាន់ទទួលបាននូវខ្សែវីដេអូទាំងមូលនៃបទសម្ភាសជាមួយ នួន ជា ដូច្នេះ ខ្សែភាពយន្តឯកសារនេះមិនអាចឲ្យគេបង្ហាញបានថាចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។ អ្នកនិពន្ធបានរៀបរាប់ និងបានកំណត់បរិបទនៃចម្លើយរបស់ នួន ជា។ មេធាវីការពារពុំអាចធ្វើការផ្ទៀងផ្ទាត់បានថា លោក នួន ជា ដែលបាននិយាយជាភាសាខ្មែរនៅក្នុងខ្សែវីដេអូនៃកិច្ចសម្ភាស ត្រូវបានគេដកស្រង់សម្ដីគ្រប់ម៉ាត់ នៅក្នុងសៀវភៅដែលសរសេរជាភាសាអង់គ្លេសនោះឡើយ។ ក្រៅពីនេះ មានតែមួយផ្នែកគត់នៃសៀវភៅនេះ ដែលត្រូវបានបកប្រែជាភាសាបារាំង និងជាភាសាខ្មែរ។ | | | | | | | | | |

ANNEX 1 : REMAINING [NON-STATEMENT] DOCUMENTS TO BE PUT BEFORE THE CHAMBER [NOT RELATING TO FORCED TRANSFER 1, 2 OR TUOL PO CHREY]]



**OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN**

| No | Prop. Party | Doc No | Type | Author | Date | Title | K ERN | E ERN | F ERN | Source |
|---|---|---|---|---|---|---|---|---|---|---|
| 5 | **Co-Prosecutors** | **E3/128** | DK Biography | LONG Norin alias Rith | > 17-Apr-1975 | Biography of LONG Narin alias Rith | 00003709-00003725 | 00754298-00754308 | 00752352-00752366 | TC Decision 8 Dec 2011 (Transcript E1/19.1, p.6) (OCP Request E131/1/4.1) |
| 6 | **Co-Prosecutors** | **E152.1.1R – E152.1.54R E152.1.1.1 – E152.1.54.1** | Video | KHIEU Samphan | To Be Determined | Khieu Samphan interview parts 1 to 54 | V00753059-V00753112, Various ERN (transcripts) | Various ERN | Various ERN | TC Decision E190.1 (OCP Request E152) |
| | **មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**<br>**ទទួលបានដោយខុសច្បាប់។**<br><br>ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន បានលើកឡើងនូវសេចក្ដីជំទាស់របស់ខ្លួនជាលាយលក្ខណ៍អក្សរ (E152/1) និងដោយផ្ទាល់មាត់។<br>បរិបទ និងកាលបរិច្ឆេទនៃឯកសារនេះមិនត្រូវបានបង្ហាញឡើយ។ ពុំមានអ្វីដែលបញ្ជាក់ថា តើលោក ខៀវ សំផន បានបញ្ចេញមតិក្នុងឋានៈជាអ្វីនោះទេ។ គេមិនអាចកំណត់អត្តសញ្ញាណរបស់អ្នកសម្ភាសនោះបានទេ។<br>ខ្សែវីដេអូត្រូវបានបង្ហោះក្នុងឆ្នាំ ២០០៧ តាមប្រព័ន្ធអ៊ីនធើណែត ដោយទុច្ចរិតពីសំណាក់បុគ្គលម្នាក់ដែលអះអាងថាខ្លួនគឺជាលោក ខៀវ សំផន។ | | | | | | | | | |
| 7 | **Co-Prosecutors** | **A190/I/15R, E190.1.297R** | Video | NUON Chea, KHIEU Samphan | ??-??-1998 | Khieu Samphan and Nuon Chea's Press Conference | None | None | None | TC Decision E190.1 |
| | **ពុំមានភាពសមហេតុសមផល។**<br>**មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**<br>**មិនអាចទទួលបានក្នុងពេលវេលាមួយសមស្រប។**<br><br>សន្និសីទសារព័ត៌មានជាមួយលោក ខៀវ សំផន និង នួន ជា នាឆ្នាំ ១៩៩៨ ក្នុងពេលដែលចុះចូលជាមួយរដ្ឋាភិបាល។ ពាក់ព័ន្ធនឹងការផ្សះផ្សាជាតិ អង្គហេតុដែលជាកម្មវត្ថុនៃរឿងក្ដីពុំត្រូវបានលើកឡើងឡើយ។ វាគ្មិនពេលខ្លះនិយាយជាភាសាអង់គ្លេស ពេលខ្លះជាភាសាខ្មែរ។ នៅក្នុងសំណុំរឿង ពុំមានការធ្វើប្រតិចារឹកពាក្យសម្ដីទាំងស្រុងឡើងវិញជាពីរភាសាឡើយ ហើយក៏ពុំមានការបកប្រែជាភាសាបារាំងដែរ។ សហព្រះរាជអាជ្ញាពុំបានបង្ហាញថា មានការធ្វើសំណើសុំណាមួយដែរ។ សំណួរមួយចំនួនស្ដាប់ពុំបាន។ ឯកសារខ្វះនូវភាពសមហេតុសមផល ហើយមិនអាចឲ្យគេបង្ហាញបានថាចង់លើកឡើងអំពីបញ្ហាអ្វី និងមិនអាចទទួលបានក្នុងរយៈពេលមួយសមស្រប។ | | | | | | | | | |
| 8 | **Co-Prosecutors** | **E93/7.3R, E93/7.2R** | Video | Sambath THET | ??-??-2000 | Interview of Nuon Chea entitled "Nuon Chea on Confessions" and "Nuon Chea on Year Zero" | V00717048-V00717048, 00714127-00714130-transcript | 00711651-00711653 | none | TC Decision E190.1 (OCP Request E93/7) |
| | **ពុំមានភាពសមហេតុសមផល។** | | | | | | | | | |

<table>
<tr><th>No</th><th>Prop. Party</th><th>Doc No</th><th>Type</th><th>Author</th><th>Date</th><th>Title</th><th>K ERN</th><th>E ERN</th><th>F ERN</th><th>Source</th></tr>
<tr><td></td><td colspan="10">មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។<br>មិនអាចទទួលបានក្នុងពេលវេលាមួយសមស្រប។<br><br>សម្រង់ខ្សែវីដេអូត្រូវបានដកស្រង់ចេញពីខ្សែភាពយន្តឯកសាររបស់ ថេត សម្បត្តិ ដែលមានចំណងជើងថា "សត្រូវរបស់ប្រជាជន" ដែលត្រូវបានសហព្រះរាជអាជ្ញាស្នើឲ្យមានការដាក់បញ្ចូលទាំងមូល។ ខ្សែភាពយន្តឯកសារនោះត្រូវបានដកស្រង់ចេញអំពីបទសម្ភាសអស់រយៈពេលជាច្រើនពាន់ម៉ោងជាមួយលោក នួន ជា ដែលក្នុងចំណោមបទសម្ភាសទាំងនោះ មានតែសម្រង់នៃកិច្ចសម្ភាសតែមួយចំនួនប៉ុណ្ណោះដែលត្រូវបានគេជ្រើសយក។ នៅខណៈដែលគេពុំទាន់ទទួលបាននូវខ្សែវីដេអូទាំងមូលនៃបទសម្ភាសជាមួយ នួន ជា ដូច្នេះ ខ្សែភាពយន្តឯកសារនេះមិនអាចឲ្យគេបង្ហាញបានថាចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។ មេធាវីការពារយល់ឃើញថា សម្រង់ខ្សែវីដេអូទាំងនេះ និង E186.1R មានលក្ខណៈច្រំដែល។ ប្រសិនណាជាអង្គជំនុំជម្រះប្រកាសថាឯកសារនេះអាចទទួលយកបាន មានតែសម្រង់ខ្សែវីដេអូសមហេតុសមផលក្នុងសំណុំរឿង ០០២/១ ទេ ដែលត្រូវទទួលយកនោះ។ ជាក់ស្តែង នៅក្នុងសំណុំរឿង ពុំមានការធ្វើប្រតិចារឹកឡើងវិញលើខ្សែភាពយន្តឯកសារនោះទាំងមូលជាបីភាសាឡើយ។ ការធ្វើប្រតិចារឹកឡើងវិញនេះមិនអាចត្រូវបានធ្វើក្នុងរយៈពេលមួយសមស្របឡើយ ហើយវាក៏ពុំមានអត្ថប្រយោជន៍ដល់យុត្តិធម៌ដែរ ក្នុងការដែលស្នើសុំឲ្យមានការធ្វើប្រតិចារឹកឡើងវិញនេះ ខណៈដែលខ្សែភាពយន្តឯកសារ និងកម្រងខ្សែវីដេអូទាំងអម្បាលម៉ាន ពុំបង្ហាញនូវភាពសមហេតុសមផលនោះ។</td></tr>
<tr><td>9</td><td>LCL Civil Parties</td><td>E109/2.3.1</td><td>Book</td><td>JENNAR Raoul Marc</td><td>To Be Determined</td><td>Livre écrit par Raoul Marc Jennar intitulé "Khieu Samphan and les Khmers Rouges"</td><td>none</td><td>none</td><td>00751207-00751552</td><td>TC Decision E190.1 (LCL List E109/2.3)</td></tr>
<tr><td></td><td colspan="10">ពុំមានភាពសមហេតុសមផល។<br>មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។<br>មិនអាចទទួលបានក្នុងពេលវេលាមួយសមស្រប។<br><br>គឺជាសៀវភៅមួយក្បាលដែលសរសេរដោយ Raoul Marc Jennar មានចំណងជើងថា " ខៀវ សំផន និងពួកខ្មែរក្រហម ៖ ចម្លើយទៅកាន់មេធាវី Vergès"។ សៀវភៅនេះដែលត្រូវបានបោះពុម្ពផ្សាយបន្ទាប់ពីមានការបើកសវនាការ មានបំណងឆ្លើយតបទៅកាន់សហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន និងថ្កោលទោសលោក ខៀវ សំផន ដោយផ្អែកលើភស្តុតាងដែលមាន។ លោក Jennar ពុំបានធ្វើការស្រាវជ្រាវលើប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងសម័យកាលកម្ពុជាប្រជាធិបតេយ្យទេ។ គាត់គឺជាទីប្រឹក្សារបស់លោក ហ៊ុន សែន និងក្នុងឋានៈជា "ពលរដ្ឋកម្ពុជា" បានធ្វើអន្តរាគមន៍ជាច្រើនលើកច្រើនសាក្នុងក្របខណ្ឌនៃរឿងក្តី (ជាឧទាហរណ៍ សូមអានអត្ថបទរបស់កាសែត Phnom Penh Post ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២។ លិខិតរបស់លោក Raoul Marc Jennar ផ្ញើទៅកាន់កាសែត Phnom Penh Post "តុលាការបានក្បត់ឧត្តមគតិនៃយុត្តិធម៌")។ គាត់មានបំណងដើរតួជំនួសចៅក្រមក្នុងការប្រកាសថា លោក ខៀវ សំផន គឺជាពិរុទ្ធជន។ ឯកសារនេះត្រូវបានតាក់តែងឡើងដោយចម្លងតាមបែបផែននៃសាលក្រម ដោយមានផ្នែកដែលរៀបរាប់អំពីអង្គហេតុ ផ្តើមដោយផ្នែកដែលលើកឡើងអំពីអង្គច្បាប់ពាក់ព័ន្ធនឹងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅចំពោះមុខ អ.វ.ត.ក. ព្រមទាំងផ្នែកដែលពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមសរសេរដោយ Véronique Marcel (ជាមនុស្សម្នាក់ដែលយើងពុំស្គាល់។ ការស្រាវជ្រាវក្នុងប្រព័ន្ធអ៊ីនធើណែតដែលបានភ្ជាប់ឈ្មោះរបស់បុគ្គលម្នាក់នេះទៅកាន់លោក Jennar បានបញ្ជាក់ឲ្យយើងដឹងថា បុគ្គលម្នាក់នេះអាចជាយុវជនម្នាក់ដែលមានអាយុ ២៤ ឆ្នាំ និងជាបុគ្គលិក"បម្រើការងារខាងផ្នែកកសិកម្ម"។ ប្រភពនៃព័ត៌មានទាំងអស់ដែលប្រើប្រាស់ដោយអ្នកនិពន្ធ ស្ថិតនៅក្នុងវិស័យសាធារណៈ ដែលមាននៅក្នុងសំណុំរឿងស៊ើបអង្កេត ឬត្រូវបានបដិសេធចោលដោយ អ.វ.ត.ក.។ វាគ្រាន់តែជាសេចក្តីសន្និដ្ឋានរបស់អ្នកនិពន្ធប៉ុណ្ណោះ។ អង្គជំនុំជម្រះបានបដិសេធចោលសំណើសុំពាក់ព័ន្ធនឹងឯកសារថ្មីដែលបានដាក់ដោយក្រុមមេធាវីការពារក្តីលោក នួន ជា ដោយមូលហេតុថា "សេចក្តីសន្និដ្ឋាននានាដែលបានធ្វើឡើងដោយអ្នកសារព័ត៌មានពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក. ទោះបីជាសេចក្តីសន្និដ្ឋាននោះជាសេចក្តីសន្និដ្ឋានថ្មីក៏ដោយ ក៏វាពុំមានតម្លៃជាភស្តុតាង និងពុំអាចឲ្យគេបង្ហាញបានអំពីអង្គហេតុដែលគេមានបំណងចង់បង្ហាញដែរ"។ យើងសូមស្នើសុំដល់អង្គជំនុំជម្រះមេត្តាប្រកាន់យកនូវជំហរដូចគ្នា ពាក់ព័ន្ធនឹងសៀវភៅមួយក្បាលនេះ ដែលអ្នកនិពន្ធបានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួន ហើយដែលសៀវភៅនេះពុំមែនជាធាតុផ្សំភស្តុតាងមួយថ្មីនោះឡើយ។</td></tr>
<tr><td>10</td><td>LCL Civil Parties</td><td>E109/2.3R (?)*</td><td>Video</td><td>SAIDNATTAR Roshane</td><td>To Be Determined</td><td>Documentary film entitled "Survive in the heart of the Khmer Rouge Madness"</td><td>V00720415</td><td>V00720415</td><td>none</td><td>TC Decision E190.1 (LCL List E109/2.3).</td></tr>
</table>

| No | Prop. Party | Doc No | Type | Author | Date | Title | K ERN | E ERN | F ERN | Source |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | *Used by LCL on 15 Feb 2012 before the Chamber (E1/44.1) but unfound as such in Zylab, E109/2.3R being the Aronowitsch and Lindberg film. |
| | **មានលក្ខណៈច្រំដែល។**<br>**ពុំមានភាពសមហេតុសមផល។**<br>**មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**<br>**មិនអាចទទួលបានក្នុងពេលវេលាមួយសមស្រប។**<br><br>ខ្សែភាពយន្តឯកសារគឺជាឯកសារដែលមានលក្ខណៈប្រឌិត ដែលលាយបញ្ចូលគ្នារវាងរូបភាពប័ណ្ណសារ និងការសំដែងត្រាប់ឡើងវិញ។ រូបភាពប័ណ្ណសារមាននៅក្នុងសំណុំរឿងរួចទៅហើយ ហើយខ្សែភាពយន្តឯកសារទៀតសោត មានលក្ខណៈច្រំដែល។ ខ្សែភាពយន្តនោះពុំបានបង្ហាញជាក់លាក់អំពីប្រធានបទដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/១ និងបានប្រាសចាកយ៉ាងឆ្ងាយអំពីក្របខណ្ឌនៃសំណុំរឿង ០០២ ទាំងមូល (សូមពិនិត្យមើល ខៀវ សំផន ដែលរៀបរាប់អំពីការចិញ្ចឹមទារបស់គាត់)។ ឯកសារនេះពុំមានភាពសមហេតុសមផលឡើយ។<br><br>ខ្សែភាពយន្តឯកសារត្រូវបានផលិតដោយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ និងបានរៀបរាប់អំពីប្រវត្តិរឿងរ៉ាវឯកជនរបស់គាត់ ដែលគាត់ទើបតែមានអាយុពី ៥ ទៅ ៨ ឆ្នាំ ប៉ុណ្ណោះកាលពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រសិនណាជាអង្គជំនុំជម្រះចាត់ទុកថាសក្ខីកម្មរបស់គាត់មានសារៈសំខាន់ ដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានកោះហៅឲ្យចូលខ្លួនក្នុងសវនាការ។ មិនតែប៉ុណ្ណោះ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អាចនឹងត្រូវបានចោទសួរពីសំណាក់ភាគីនៃរឿងក្តីផងដែរ។<br><br>ខ្សែភាពយន្តឯកសារពុំមានជាភាសាខ្មែរទេ ហើយមាននៅក្នុងសំណុំរឿងតែជាភាសាអង់គ្លេស។ ធាតុផ្សំភ័ស្តុតាងត្រូវតែបានបកប្រែជាបីភាសាផ្លូវការនៅ អ.វ.ត.ក.។ ការធ្វើប្រតិចារឹកឡើងវិញទៅលើខ្សែភាពយន្តឯកសារទាំងមូលជាភាសាខ្មែរ ពុំត្រូវបានជាប្រយោជន៍ដល់យុត្តិធម៌ទេ ខណៈដែលខ្សែភាពយន្តឯកសារនេះទាំងមូលពុំមានចរិតលក្ខណៈសមហេតុសមផល និងពុំអាចឲ្យទទួលបានក្នុងរយៈពេលមួយសមស្របនោះ។ | | | | | | | | | |
| 11 | **LCL Civil Parties and Co-Prosecutors** | **E186.1R** | Video | Sambath THET and LEMKIN Rob | To Be Determined | Documentary film entitled “Enemies of the people” (Nuon Chea interview) and 16 additional footages | V00800935-V00800935 | V00800935-V00800935 | none | TC Decision E190.1 (LCL List E109/2.3) |
| | សូមពិនិត្យមើលកំណត់សម្គាល់នានាដែលពាក់ព័ន្ធនឹងឯកសារលេខ ៨ នៃតារាង។ | | | | | | | | | |
| 12 | **Ieng Sary** | **D172.6** | Book | CHANDLER David | 01-Apr-1977 | Attachment 5 entitled “Transformation in Cambodia”, Commonwealth | 00818590-00818600 | 00335745-00335748 | 00825588-00825591 | TC Decision E172/24/4 (IS Request, E172/24/3 (F)) |
| 13 | **Ieng Sary** | **E190.1.407** | Book | VICKERY Michael | ??-??-1981 | Book entitled “Democratic Kampuchea: Themes and Variations” | | S 00047272-00047299, S 00047300- | | TC Decision E190.1 (IS List E109/6.2) |

**ANNEX 1 : REMAINING [NON-STATEMENT] DOCUMENTS TO BE PUT BEFORE THE CHAMBER [NOT RELATING TO FORCED TRANSFER 1, 2 OR TUOL PO CHREY]]**



**OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN**

| No | Prop. Party | Doc No | Type | Author | Date | Title | K ERN | E ERN | F ERN | Source |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | 00047329 | | |
| 14 | **Ieng Sary** | **E190/2.2** | Book | OSBORNE Milton | ??-??-1994 | Book entitled "Sihanouk, Prince of Light, Prince of Darkness" | none | 00808150-00808309 | none | TC Decision E190/2.1 (found under the Shared Material Drive only) |
| | ដើម្បីឲ្យស៊ីសង្វាក់គ្នា ក្រុមមេធាវីការពារក្តីលោក អៀង សារី បានបង្ហាញថា ខ្លួនលែងទាមទារឲ្យមានការទទួលស្គាល់ឯកសារនេះថាជាធាតុផ្សំភ័ស្តុតាងទៀតហើយ។ លោក ខៀវ សំផន នឹងមិនទាមទារឲ្យមានការសម្រេចអំពីភាពដែលអាចទទួលយកបាននៃឯកសារនេះឡើយ។ | | | | | | | | | |
| 15 | **Ieng Sary** | **D22/2052.1** | Media Article | GILLISON Douglas, LY HOR | 28-Aug-2000 | Article entitled "177 released from S-21, DC-Cam Records show"; LY HOR (civil party) biographical database | 00814871-00814873 | 00548253-00548256 | 00836686-00836691 | TC Decision E172/24/4 (IS Request, E172/24/3 (K)) |
| 16 | **Khieu Samphan** | **E190/2.6, D153.12** (updated version 2009) | Academic Article | KIERNAN Ben, OWEN Taylor | ??-Oct-2006 | Article entitled "Bombs over Cambodia" | none | 00809335-00809338 | none | TC Decision E190/2.1 |
| 17 | **Khieu Samphan** | **E190/2.10** | Book | KIERNAN Ben | > ??-04-1987 | Book entitled "The US Bombardment of Cambodia, 1969-1973, Vietnam Generation" | none | 00809342-00809360 | none | TC Decision E190/2.1 |
| 18 | **Khieu Samphan** | **E190/2.11** | Book | KILJUNEN Kimmo | ??-??-1984 | Kampuchea decade of the genocide (Third World Studies): Report of a Finnish Inquiry Commission | none | 00809361-00809435 | none | TC Decision E190/2.1 |
| 19 | **Khieu Samphan** | **E190/2.13** | Int'l Communication | US Department of State | 09-Dec-1970 | Transcription of a conversation between Nixon and Kissinger | none | 00809451-00809457 | none | TC Decision E190/2.1 |
| 20 | **Khieu Samphan** | **E190/2.14** | Int'al Communication | US Department of State | 09-Dec-1970 | Transcription of a conversation between Kissinger and General Haig | none | 00809458-00809460 | none | TC Decision E190/2.1 |
| 21 | **Khieu Samphan** | **E190/2.16** | Int'l Communication | US Department of State | ??-??-1975 | Memorandum of a conversation between Indonesian President Suharto and Ford & Kissinger | none | 00809480-00809491 | none | TC Decision E190/2.1 |
| 22 | **Khieu Samphan** | **E190/2.15** | Int'l Communication | US Department of State | 26-Nov-1975 | Memorandum of conversation : Secretary's Meeting with Foreign Minister Chatchai of Thailand » | none | 00809461-00809479 | none | TC Decision E190/2.1 |
| 23 | **Khieu Samphan** | **E190.1.408** | Int'l Communication | French Ministry of Foreign Affairs, PECH Lim Kuon | 11-Aug-1976 | Notes from French Diplomat entitled "Conversation with PECH Lim Kuon" | 00823179-00823181 | 00823177-00823178 | 00389075-00389077 | TC Decision E190.1 (KS List E109/1.1) |
| 24 | **Khieu Samphan** | **E190/2.9** | Int'l Communication | UN General Assembly | 14-Nov-1979 | Résolution de l'Assemblée Génerale des Nations Unies, 34 ème session, la Situation au Kampuchea, A/RES/34/22 | none | None | 00809341-00809341 | TC Decision E190/2.1 |
| 25 | **Khieu Samphan** | **E190/2.17** | Int'l Media Report | CHOMSKY Noam (NY Review of Books) | 04-Jun-1970 | A Special Supplement: Cambodia, The New York Review of Books, Noam Chomsky | none | 00809492-00809526 | none | TC Decision E190/2.1 |

# ANNEX 1 : REMAINING [NON-STATEMENT] DOCUMENTS TO BE PUT BEFORE THE CHAMBER [NOT RELATING TO FORCED TRANSFER 1, 2 OR TUOL PO CHREY]]



## OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN

| No | Prop. Party | Doc No | Type | Author | Date | Title | K ERN | E ERN | F ERN | Source |
|---|---|---|---|---|---|---|---|---|---|---|
| **26** | **Khieu Samphan** | **E190.1.412** | Int'l Media Report | AFP | 16-Dec-1975 | Dépêche de l'AFP intitulée "Arrivée d'une délégation laotienne en visite au Cambodge" | none | None | 00391115-00391115 | TC Decision E190.1 (KS List E109/1.1) |
| **27** | **Khieu Samphan** | **E190.1.411** | Int'l Media Report | The TIMES | 04-May-1976 | Article entitled "Defecting Khmer Rouge helicopter pilot tells of life in Phnom Penh" by The Times | S 00752666-00752668 | S 00005730-00005730 | S 00752467-00752468 | TC Decision E190.1 (KS List E109/1.1) |
| **28** | **Khieu Samphan** | **E190.1.409** | Int'l Media Report | HERALD TRIBUNE | 11-May-1976 | Article entitled "Escape because of Khmer brutality" | S 00753046-00753048 | S 00005745-00005745 | S 00752469-00752470 | TC Decision E190.1 (KS List E109/1.1) |
| **29** | **Khieu Samphan** | **E190.1.410** | Int'l Media Report | NEWSWEEK | 17-May-1976 | Article entitled "Cambodia: Two Views from Inside" | S 00774492-00774496 | S 00005751-00005752 | S 00752471-00752473 | TC Decision E190.1 (KS List E109/1.1) |
| **30** | **Khieu Samphan** | **E190/2.8** | Int'l Media Report | SHAWCROSS William (Far East Economic Review) | 07-Jan-1977 | Article entitled "Cambodia: The verdict is guilty on Nixon and Kissinger" | none | S 00006020-00006046 | none | TC Decision E190/2.1 |
| **31** | **Khieu Samphan** | **E190/2.5** | Letter | JULLIAN-GAUFRES Phillipe | 15-Oct-2010 | Letter of Philippe Jullian-Gaufres in favour of Khieu Samphan | none | none | 00809322-00809334 | TC Decision E190/2.1 |
| **32** | **Khieu Samphan** | **E190/2.7** | Letter | SAM Sok | 21-Jan-2011 | Letter of Sam Sok in favour of Khieu Samphan | none | none | 00809339-00809340 | TC Decision E190/2.1 |
| **33** | **Khieu Samphan** | **E190/2.18** | Letter | DUMAS Roland | 14-Feb-2011 | Letter of Roland Dumas in favour of Khieu Samphan | none | none | 00809527-00809527 | TC Decision E190/2.1 |
| **34** | **Khieu Samphan** | **E190/2.19** | Letter | KATZ Claude | 18-Apr-2011 | Letter of Mrs Claude Katz in favour of Khieu Samphan | none | none | 00809528-00809531 | TC Decision E190/2.1 |
| **35** | **Khieu Samphan** | **E190/2.4** | Media Article | PICQ Laurence, DESGOUTTES Jean-Paul | ??-06-1984 | Article entitled « Entretien avec Laurence Picq, juin 1984 » | none | None | 00809313-00809321 | TC Decision E190/2.1 |
| **36** | **Khieu Samphan** | **E190/2.20** | Media Article | McLEOD George (Phnom Penh Post) | 27-Mar-2009 | Article entitled « Noam Chomsky Interview by George McLeod » | none | 00809532-00809535 | none | TC Decision E190/2.1 |
| **37** | **Khieu Samphan** | **E190/2.12** | Media Article | KIERNAN Ben, OWEN Taylor | 28-Jun-2010 | Article entitled "Roots of the US Troubles in Afghanistan: Civilian Bombing Casualties and the Cambodian precedent" | none | 00809436-00809450 | none | TC Decision E190/2.1 |
| **38** | **Nuon Chea** | **E131/1/13.3** | Academic Article | HEDER Stephen | ??-??-1997 | Article by Steve Heder entitled "Racism, Marxism, Labelling and Genocide in Ben Kiernan's The Pol Pot Regime" | 00844550-00844616 | 00773700-00773771 | 00802800-00802833 | TC Decision E190.1 (NC List E131/1/13.1) |
| **39** | **Nuon Chea** | **E131/1/13.12** | Book | BRINKLEY Joel | ??-??-2011 | Excerpt of book by JOEL Brinkley entitled "Cambodia's Curse, The modern history of a troubled land" | 00778348-00778376 | 00773832-00773847 | 00788878-00788894 | TC Decision E190.1 (NC List E131/1/13.1) |
| **40** | **Nuon Chea** | **E131/1/13.8** | Int'l Communication | USGAO | 30-Apr-1974 | USGAO Report entitled "Report to the subcommittee on refugees and escapees committee on the judiciary United States Senate" | 00777559-00777593 | 00773774-00773804 | none | TC Decision E190.1 (NC List E131/1/13.1) |
| **41** | **Nuon Chea** | **E131/1/13.6** | Int'l Media Report | SHIPLER David | 19-Jul-1973 | Article by The New York Times "Saigon, Podded by U.S., Lends Rice to | 00775769-00775771 | 00773773-00773773 | 00789699-00789700 | TC Decision E190.1 (NC List |

## ANNEX 1 : REMAINING [NON-STATEMENT] DOCUMENTS TO BE PUT BEFORE THE CHAMBER [NOT RELATING TO FORCED TRANSFER 1, 2 OR TUOL PO CHREY]]



## OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN

| No | Prop. Party | Doc No | Type | Author | Date | Title | K ERN | E ERN | F ERN | Source |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Cambodia" | | | | E131/1/13.1) |
| **42** | **Nuon Chea** | **E131/1/13.4** | Int'l Media Report | SCHANBERG Sydney (The New York Times) | 19-Mar-1975 | Article entitled "A Cambodian Anniversary Marked only by misery" | 00775762-00775768 | 00773772-00773772 | 00789695-00789698 | TC Decision E190.1 (NC List E131/1/13.1) |
| **43** | **Nuon Chea** | **E131/1/13.7** | Int'l Media Report | Angus DEMING (Newsweek) | 22-Jan-1979 | Article entitled "Phnom Penh New Rulers" | 00775750-00775752 | 00774423-00774423 | 00786104-00786106 | TC Decision E190.1 (NC List E131/1/13.1) |
| **44** | **Nuon Chea** | **E131/1/13.5** | Media Article | SCHANBERG Sydney (The New York Times) | 26-Feb-1975 | Article entitled "Children starving in once-Lush Land" | none | 00750864-00750865 | none | TC Decision E190.1 (NC List E131/1/13.1) |
| **45** | **Nuon Chea** | **E131/1/13.2** | Media Article | T.D. ALLMAN (Vanity Fair) | ??-Apr-1990 | Article by T.D. Allman in Vanity Fair entitled "Sihanouk's Sideshow" | 00793942-00793979 | 00773684-00773699 | none | TC Decision E190.1 (NC List E131/1/13.1) |
| **46** | **Nuon Chea** | **E131/1/13.9** | Report | US Senate SFRC | 27-Apr-1973 | U.S. Air Operations in Cambodia: April 1973 | 00777594-00777613_ | 00773805-00773818 | 00789655-00789671 | TC Decision E190.1 (NC List E131/1/13.1) |
| **47** | **Nuon Chea** | **E131/1/13.11** | Report | PRK Council of Ministers | 23-Aug-1986 | Decision - K-5 Construction plan for fiscal year 1987 - The Council of Minister | 00774424-00774428 | 00773822-00773831 | 00793316-00793327 | TC Decision E190.1 (NC List E131/1/13.1) |
| **48** | **Nuon Chea** | **E131/1/13.10** | Report | Cambodian & Thai Governements | 06-07-May-1998 | Working visit to Thailand of H.E. Second Prime Minister HUN Sen | none | 00773819-00773821 | none | TC Decision E190.1 (NC List E131/1/13.1) |